**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៦

នៅក្នុងខែមីនា ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម រួមមាន៖**

❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

១- ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និង

២- វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៨ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធាន (ក.ជ.ប.ព) នៅអង្គភាពប្រឆាំងអំពើពុករលួយ។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

**២-មុខងារតាមដានការអនុវត្តច្បាប់**

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា៖**
  - ❖ គណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃក្រសួងអធិការកិច្ច ដឹកនាំដោយ **ឯកឧត្តម សុខ សូកេន** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់ក្រសួង និងកិច្ចសហការការងារ នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា
  - ❖ គណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ៖
    - **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារក្នុងវិស័យមូលបត្រកម្ពុជា ឱកាស បញ្ហាប្រឈម និងផែនការនាពេលអនាគតរបស់និយ័តករមូលបត្រកម្ពុជាទាំងរយៈពេលខ្លី និងរយៈពេលវែង នៅទីស្ដីការគណៈកម្មការមូលបត្រកម្ពុជា។
    - **លោក កួវ ណុច** ប្រធាននាយកដ្ឋាន និង**អ្នកឧកញ៉ា ជា ទ្រី** អគ្គនាយកក្រុមហ៊ុន ហុង ឡេងហួរ គ្រុប ដើម្បីឈ្វេងយល់អំពី៖ ១-វឌ្ឍនភាពការងាររបស់នាយកដ្ឋានគយ និងរដ្ឋាករផែស្ងួត ក្នុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ ២-ការប្រមូលចំណូលរបស់ការិយាល័យគយ និងរដ្ឋាករផែស្ងួត ហុង ឡេងហួរ ក្នុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ ៣-ទិដ្ឋភាពសេដ្ឋកិច្ច សក្ដានុពល បញ្ហាប្រឈមនៃការប្រមូលចំណូលក្នុងផែស្ងួត និង ៤-ប្រតិបត្តិការសំខាន់ៗក្នុងផែស្ងួត នៅការិយាល័យគយ និងរដ្ឋាករផែស្ងួត ហុង ឡេងហួរ រាជធានីភ្នំពេញ។
    - **ឯកឧត្តម ហ៊ី បារី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធាន អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ ដើម្បីឈ្វេងយល់អំពី៖ ១-វឌ្ឍនភាពការងាររបស់កំពង់ផែស្វយ័តភ្នំពេញ សក្ដានុពល ចក្ខុវិស័យ និងផែនការអនាគត ២-ការប្រមូលចំណូលរបស់ការិយាល័យគយ និងរដ្ឋាករប្រចាំកំពង់ផែ និង៣-ទិដ្ឋភាពសេដ្ឋកិច្ចក្នុងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី២ នៅខេត្តកណ្ដាល។
    - រដ្ឋបាលខេត្តត្បូងឃ្មុំ និងអង្គភាពពាក់ព័ន្ធ រដ្ឋបាលខេត្តមណ្ឌលគិរី និងអង្គភាពពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលស្រុកអូររាំង នៅខេត្តត្បូងឃ្មុំ និង
    - ទស្សនកិច្ចច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តត្បូងឃ្មុំ និងតំបន់អាជីវកម្មរ៉ែមាសអូរខ្វាវរបស់ក្រុមហ៊ុន រីណែសង់ ខេមបូឌាលីមីធីត ខេត្តមណ្ឌលគិរី។
  - ❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ៖
    - **ឯកឧត្តម ឆាយ ឫទ្ធិសែន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង**ឯកឧត្តម ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនានាក្នុងឆ្នាំ២០២៥ និងទិសដៅការងាររបស់ក្រសួងសម្រាប់ឆ្នាំ២០២៦ នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ និងទីស្ដីការក្រសួងផែនការ និង

- **ឯកឧត្តម ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត ថ្នាក់ដឹកនាំក្រុង ស្រុក ឃុំ សង្កាត់ និងមន្ទីរជំនាញដែលជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពត ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពត។

❖ គណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តក្រចេះ ដឹកនាំដោយ **ឯកឧត្តម វ៉ា ថន** អភិបាលនៃគណៈអភិបាលខេត្តក្រចេះ ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលមហោស្រព ខេត្តក្រចេះ។

❖ គណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃក្រសួងព័ត៌មាន ដឹកនាំដោយ **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីឈ្វេងយល់អំពីសមិទ្ធផលការងារ ដែលក្រសួងព័ត៌មានសម្រេចបានក្នុងឆ្នាំ២០២៥ និងទិសដៅការងារអនុវត្តបន្តសម្រាប់ឆ្នាំ២០២៦ ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៥ នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

❖ គណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចុះពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មៀនឃុំ-សង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ នៅតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពី "ការចុះបញ្ជីអត្រានុកូលដ្ឋាន" និងតាមដានការអនុវត្តច្បាប់នៅថ្នាក់ក្រោមជាតិ និងតុលាការ នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

❖ គណៈកម្មការទី៧ព្រឹទ្ធសភា៖

- បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងទិសដៅបន្តនៃការអនុវត្តន៍គោលនយោបាយអប់រំនៅបឋមសិក្សា នៅសាលប្រជុំទីស្តីការក្រសួងអប់រំ យុវជន និងកីឡា និង
- បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងចក្ខុវិស័យទៅមុខរបស់រដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធវិស័យជាសមត្ថកិច្ច នៅខេត្តកំពត និងខេត្តព្រះសីហនុ។

❖ គណៈកម្មការទី៨ព្រឹទ្ធសភា៖

- បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងចុះទស្សនកិច្ចឈ្វេងយល់ពីវឌ្ឍនភាពលើវិស័យការងារ សង្គមកិច្ច សុខាភិបាល និងកិច្ចការនារី នៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តតាកែវ និង
- បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជូនកងពលតូចអន្តរាគមន៍លេខ៩ តំបន់ប្រតិបត្តិការសឹករងខេត្តព្រះវិហារ ខេត្តកំពង់ធំ និងមន្ទីរពេទ្យបង្អែកស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយៈ

- **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង**ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន។
- **ឯកឧត្តម ខៀវ រិទ្ធិភ័ណ្ឌ** អភិបាលរងខេត្តកំពត និង**ឯកឧត្តម ម៉ែន វិបុល** ប្រធានក្រុមប្រឹក្សាខេត្ត និងប្រធានមន្ទីរជំនាញពាក់ព័ន្ធ ស្តាប់របាយការណ៍របស់ **ឯកឧត្តម សរ សុជានី** អភិបាលរងខេត្ត និងបានទស្សនកិច្ចកំពង់ផែពហុបំណងកំពត កំពង់ផែទេសចរណ៍អន្តរជាតិកំពត តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត នៅខេត្តកំពត និង
- បានអញ្ជើញទស្សនកិច្ចនៅក្រុមហ៊ុន VP.Start Technology Co., Ltd នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

**- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ**

❖ **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឱ បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងជំនួបពិភាក្សាការងាររវាងគណៈកម្មការទី៥ព្រឹទ្ធសភា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឺវ យីស៊ាង** ប្រធានគណៈកម្មការទី៥ ជាមួយក្រសួងព័ត៌មាន ដឹកនាំដោយ **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅសាលកក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

## ៣-មុខងារតំណាង

**- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមានៈ**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាៈ**

- **សកម្មភាពចូលរួមពិធីផ្សេងៗៈ**
  - បានអញ្ជើញបន្តតាមដានដោយយកចិត្តទុកដាក់ខ្ពស់ចំពោះការវិវត្តសភាពការណ៍ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង
  - បានអញ្ជើញចុះសាកសួរសុខទុក្ខ និងសំណេះសំណាលជាមួយនាយក្រិន ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១**ព្រឹទ្ធសភាៈ**

- **បេសកកម្មក្នុងប្រទេសៈ**
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីក្រុង៣លី ចម្រើនអាយុវឌ្ឍនមង្គល **ព្រះវិរិយានុបាល សេង ពេជ្រ** ព្រះចៅអធិការវត្តព្រះអង្គកងជុំ សម្ពោធឆ្លងកុដិ និងបុណ្យផ្កាប្រាក់សាមគ្គី ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅវត្តព្រះអង្គកងជុំ ខេត្តសៀមរាប។

- បានអញ្ជើញជួបសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួស ខែរ៉ាម៉ាឌន ជូនប្រជាពលរដ្ឋខ្មែរ-ឥស្លាម ប្រមាណជាង៤០០គ្រួសារ នៅក្នុងសង្កាត់សំបួរមាស ក្រុងកំពង់ចាម និងឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម និង
- បានអញ្ជើញចុះជួបសំណេះសំណាល ផ្សព្វផ្សាយសភាពការណ៍កម្ពុជា និងសមិទ្ធផលនានា ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីរាជការ ប្រជាពលរដ្ឋ នៅទូទាំងក្រុង ស្រុកនៃខេត្តកំពង់ចាម។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល អបអរសាទរខួបលើកទី១១៥ (១៩១១-២០២៦) ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ "សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ" នៅសាលអាហារភិរម្យ វិមានសាមគ្គីភាព។
- បានអញ្ជើញចូលរួមក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៦ របស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា នៅសណ្ឋាគារ Hyatt Regency Phnom Penh និង
- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ នៅសាលអាហារភិរម្យ វិមានសាមគ្គីភាព។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខឿន្សនា អនុប្រធានទី២ព្រឹទ្ធសភា៖**

▪ **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**

- បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីតាមដាន និងសម្របសម្រួលកិច្ចការជាប្រយោជន៍របស់ប្រជាពលរដ្ឋតាមភូមិភាគ និងអំពីសមិទ្ធផល ឬបញ្ហាប្រឈម និងសំណូមពរ បានសម្រេច/ដោះស្រាយ ប្រចាំខែកុម្ភៈ នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយសមាជិក សមាជិកា និងក្រុមជំនួយការនៃគណៈកម្មការពិសេស ដើម្បីពិគ្រោះយោបល់ត្រៀមលក្ខណៈចូលរួមការពារសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ វិមានព្រឹទ្ធសភា និង
- បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីការរៀបចំរបាយការណ៍នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី៤ និងលើកទី៥ នៅសាលភក្តីវិក្រម៣ វិមានព្រឹទ្ធសភា។

▪ **សកម្មភាពចុះមូលដ្ឋាន៖** បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធមកពីទូទាំងសង្កាត់នៃខណ្ឌជ្រោយចង្វារ

រាជធានីភ្នំពេញ នៅសាលភក្តីរ៉ៃក្រម១ វិមានព្រឹទ្ធសភា។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាក្នុងពិធីបិទសិក្ខាសាលាស្តីពី "ការពង្រឹងភាពធន់ជាតិ និងកាលានុវត្តភាពនៃយុទ្ធសាស្ត្រអភិបាលកិច្ចវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា" នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា និង
  - បានអញ្ជើញសួរសុខទុក្ខ និងចូលរួមពិធីបុណ្យសព **លោក ទេព ថាវរិទ្ធ** អតីតមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំង គ្រឿងញៀនខុសច្បាប់លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៥ (១៩១១-២០២៦) ទិវាអន្តរជាតិនារី ៨ មីនា ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា និង**លោកជំទាវ** ក្រោមប្រធានបទ "សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ" នៅសាលអាហារភិរម្យ វិមានសាមគ្គីភាព។
- បានអញ្ជើញជាកិត្តិយសក្នុងពិធីសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួសខែរ៉ាម៉ាឌន ជូនប្រជាពលរដ្ឋខ្មែរ-ឥស្លាម ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅក្រុងកំពង់ចាម និងស្រុកកងមាស ខេត្តកំពង់ចាម។
- បានអញ្ជើញជាកិត្តិយសក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ស្ថិតនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។
- បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "ការពង្រឹងភាពធន់ជាតិ និងកាលានុវត្តភាពនៃយុទ្ធសាស្ត្រអភិបាលកិច្ចវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតយកថ្លៃ នៅខេត្តត្បូងឃ្មុំ។
- បានអញ្ជើញធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូននិស្សិតនៃសាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៅសាលភក្តីរ៉ៃក្រម១ វិមានព្រឹទ្ធសភា។

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន និងឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១៣៩លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៦០លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានចូលរួមអមដំណើរ **ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត យូ ស៊ុនឡុង** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពង់ចាម ដឹកនាំដោយ **ឯកឧត្តម អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងរដ្ឋបាលខេត្តត្បូងឃ្មុំ ដឹកនាំដោយ **ឯកឧត្តម ប៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ដើម្បីត្រៀមរៀបចំសម្របសម្រួលការអញ្ជើញចុះបំពេញមុខងារតំណាងរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នាពេលខាងមុខ ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល អបអរសាទរខួបលើកទី១១៥ (១៩១១-២០២៦) ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ "សន្តិភាព និងសន្តិសុខ សម្រាប់ស្ត្រី និងគ្រួសារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលអាហារភិរម្យ វិមានសាមគ្គីភាព។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកថវិការបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនអាជ្ញាធរសង្កាត់ព្រែកតាសេក និងបានឧបត្ថម្ភថវិកា ចូលរួមបុណ្យដាភូមិ នៅភូមិព្រែកតាវ័ន្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម មុំ អោម** ទីប្រឹក្សារាជរដ្ឋាភិបាល ត្រូវជាឪពុកបង្កើតរបស់ **ឯកឧត្តម មុំ រ៉ាវីន** នាយករងខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅខេត្តស្វាយរៀង និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក។

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។
- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញនាំយកថវិកាដែលជាអំណោយរបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនអាជ្ញាធរសង្កាត់ព្រែកលៀប និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤លើក។
- **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមពិធីផ្សេងៗ ចំនួន៤លើក។

- បានរៀបចំអំណោយ ចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង
- បានទទួលពាក្យបណ្ដឹង ចំនួន៤បណ្ដឹង បញ្ជូនពាក្យបណ្ដឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន៩បណ្ដឹង កំពុងពិនិត្យសិក្សា ចំនួន២បណ្ដឹង តម្កល់ទុកមិនចាត់ការ ចំនួន២បណ្ដឹង និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន២បណ្ដឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទី ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**
  - **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី៖**
    - **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបប្រគល់សារតាំង ពិភាក្សាការងារ និងសម្ដែងការគួរសម ចំនួន៩លើក នៅវិមានសាមគ្គីភាព រួមមាន៖
      - **លោកជំទាវ** Katharina Wieser ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអូទ្រីស។
      - **ឯកឧត្តម** Alexander MicovxČin ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋស្លូវ៉ាគី។
      - **ឯកឧត្តម** Sonexay Vannaxay ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
      - **លោកជំទាវ** Teo Lay Cheng ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី។
      - **ឯកឧត្តម** Danny Annan ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រដាណឺម៉ាក។
      - **លោកជំទាវ** Louise Mushikiwabo អគ្គលេខាធិការអង្គការអន្តរជាតិនៃក្រុមប្រទេសនិយាយភាសាបារាំង (Organisation Internationale de la Francophonie)។
      - **ឯកឧត្តម** Peter Altmann សមាជិកក្រុមប្រឹក្សាភិបាលនៃគណបក្សជម្រើសថ្មី AFD មូលដ្ឋានប្រចាំទីក្រុង Karlsurhe សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។
      - **ឯកឧត្តម** Kairat Sarybay អគ្គលេខាធិការនៃសន្និសីទស្តីពី អន្តរកម្ម និងវិធានការ

កសាងទំនុកចិត្តនៅអាស៊ី (Conference on Interaction and Confidence Building Measures in Asia-CICA) និង

- ថ្នាក់ដឹកនាំក្រុមព្រៃឡង់។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖**
  - បានអនុញ្ញាតឱ្យ **ឯកឧត្តម Kim Changyong** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព។
  - បានអនុញ្ញាតឱ្យ **ឯកឧត្តមបណ្ឌិត György Such** អគ្គលេខាធិការរដ្ឋសភាហុងគ្រី ចូលជួបសម្តែងការគួរសម និងធ្វើជាអធិបតី ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាហុងគ្រី នៅវិមានសាមគ្គីភាព។
  - បានអនុញ្ញាតឱ្យ **ឯកឧត្តម Park Joo Bong** ទីប្រឹក្សាឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានពាណិជ្ជកម្ម ឧស្សាហកម្ម ទីក្រុង Incheon និងជាអគ្គនាយកក្រុមហ៊ុន Daejoo CK Group នៅបន្ទប់ប្រជុំរបស់ឯកឧត្តម និង
  - បានអនុញ្ញាតឱ្យ **លោក ញាណ សុជាតិ** ជាបេក្ខជនបណ្ឌិតផ្នែក Southeast Asian Studies នៅសាកលវិទ្យាល័យ Humboldt University of Berlin សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ចូលជួបសម្ភាសន៍ ដើម្បីសរសេរនិក្ខេបបទថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យ Humboldt University of Berlin។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទង្សេនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអញ្ជើញជួបពិភាក្សាការងារជាមួយ **លោកសាស្ត្រាចារ្យ Lee Hyun-Hoon** មកពីសាកលវិទ្យាល័យជាតិ Kangwon នៃសាធារណរដ្ឋកូរ៉េ នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ វិមានសាមគ្គីភាព។

❖ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំសន្និសីទ ISC លើកទី២ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ វិមានសាមគ្គីភាព។

❖ **ឯកឧត្តមបណ្ឌិត ឈឺវ យីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និង**ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម Yoon Ju-Duk** សមាជិករដ្ឋសភាកូរ៉េ និងជាប្រធានក្រុមមិត្តភាពសភាកូរ៉េកម្ពុជា នៅសាលភក្តីវិក្រមា វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលអំណោយមនុស្សធម៌លើកទី១៧ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ រួមមាន

ឱសថ សម្ភារវេជ្ជសាស្ត្រ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ នៅវិមានព្រឹទ្ធសភា។

- ❖ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និង**លោកជំទាវ មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមដើម្បីរៀបចំវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកស្ដីពី សុខភាពសកល លើកទី៩ (9th APPF - GH) នៅវិមានរដ្ឋសភា និង

- ❖ **សម្ដេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងដង្ហែព្រះរាជសវនាការ **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការទទួលជួប **លោកជំទាវ** Teo Lay Cheng ឯកអគ្គរដ្ឋទូតនៃប្រទេសសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលក្រាបថ្វាយបង្គំលា ក្នុងឱកាសដែលលោកជំទាវឯកអគ្គរដ្ឋទូតបានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
    - ▪ បានអញ្ជើញចូលរួមអម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី ក្នុងពិធីប្រគល់សារតាំង ពិភាក្សាការងារ និងសម្ដែងការគួរសម ជាមួយភ្ញៀវជាតិ-អន្តរជាតិ នៅវិមានសាមគ្គីភាព ចំនួន៩លើក។
    - ▪ បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា ក្នុងជំនួបសម្ដែងការគួរសម ជាមួយ **ឯកឧត្តមបណ្ឌិត** György Such អគ្គលេខាធិការរដ្ឋសភាហុងគ្រី នៅវិមានសាមគ្គីភាព។
    - ▪ បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាហុងគ្រី ជាមួយ **ឯកឧត្តមបណ្ឌិត** György Such អគ្គលេខាធិការរដ្ឋសភាហុងគ្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា នៅវិមានសាមគ្គីភាព។
    - ▪ បានអញ្ជើញចូលរួមកម្មវិធីជប់លៀងអបអរសាទរទិវាអន្តរជាតិហ្វ្រង់កូហ្វូនី ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសណ្ឋាគារ Rosewood Phnom Penh។
    - ▪ បានអញ្ជើញទទួលជួបជាមួយភ្ញៀវអន្តរជាតិ ចំនួន២លើក នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា វិមានសាមគ្គីភាព រួមមាន៖
      - **លោក** Li Guodong លេខាធិការទី១ និង**លោក** Zhang Yuntao លេខាធិការទី២ នៃការិយាល័យសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន

ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ និង

- **លោកបណ្ឌិត** David Zhan នាយកប្រតិបត្តិនៃក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា និងសហការី ដើម្បីពិភាក្សាអំពីផែនការអភិវឌ្ឍ និងលើកកម្ពស់វិស័យទេសចរណ៍កម្ពុជា តាមរយៈការបន្តពង្រីកការតភ្ជាប់ជើងហោះហើរត្រង់ជាមួយបណ្តាប្រទេសនានា ក្នុងតំបន់។

❖ **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី ក្នុងពិធីប្រគល់សារតាំង ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ-អន្តរជាតិ នៅវិមានសាមគ្គីភាព ចំនួន៩លើក។

- បានសហការ និងទាក់ទងជាមួយមជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែកុម្ភៈ-ខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៦ នៅសាលកក្តីវិក្រម១ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀត ដោយមានការចូលរួមពីអគ្គលេខាធិការរង និងអគ្គនាយក អគ្គនាយិកានៃអគ្គនាយកដ្ឋាន អំពីរបៀបរបបការងាររបស់អគ្គលេខាធិការដ្ឋាន និងការប្រគល់សិទ្ធិលើកិច្ចការងារមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋាននីមួយៗ ព្រមទាំងពិភាក្សាលើការងារត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ និងកម្មវិធីសំខាន់ៗ នៅវិមានសាមគ្គីភាព។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀត ដោយមានការចូលរួមពីអគ្គលេខាធិការរង និងអគ្គនាយក អគ្គនាយិកានៃអគ្គនាយកដ្ឋាន ដើម្បីពិភាក្សារបៀបវារៈសំខាន់៣ រួមមាន៖ (១) ការពិនិត្យលើបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា ក្នុងទម្រង់រូបរាងថ្មី និងការរៀបចំមាតិកាបន្ថែម ឱ្យស្របទៅតាមបរិបទ និងការវិវត្តថ្មីៗនៃព្រឹទ្ធសភា នីតិកាលទី៥ (២) ការរៀបចំសម្របសម្រួលការអញ្ជើញចុះបំពេញមុខងារតំណាងរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និង(៣) ការរៀបចំកម្មវិធីសិក្ខាសាលា និងកិច្ចប្រជុំគណៈកម្មការនយោបាយ (APF) នៅខេត្តសៀមរាប និងការត្រៀមធ្វើជាម្ចាស់ផ្ទះសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅកម្ពុជា នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា វិមានសាមគ្គីភាព។

- បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀតជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្តីពីគម្រោងសាងសង់អគារថ្មីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា វិមានសាមគ្គីភាព។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ នៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលអាហារភិរម្យ វិមានសាមគ្គីភាព។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** បានអញ្ជើញចុះពិនិត្យទីតាំងសម្រាប់ការដ្ឋានសាងសង់អគារថ្មីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិនិត្យបច្ចុប្បន្នភាពសំណង់អគារនានា ស្ថិតក្នុងបរិវេណវិមានព្រឹទ្ធសភា។

- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញជាអធិបតីក្នុងពិធីដេញថ្លៃ ស្តីពី ការផ្គត់ផ្គង់ប្រេងឥន្ធនៈ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលភក្តីវិក្រម៥ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ នៅអគារអគ្គនាយកដ្ឋានពន្ធដារ។

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៦ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលភក្តីវិក្រម៥ វិមានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- ចំណាយត្រីមាសទី២ និងបោះផ្សាយអាណត្តិត្រីមាសទី២ ឆ្នាំ២០២៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានចុះក្នុងប្រព័ន្ធFMIS។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមីនា ឆ្នាំ២០២៦ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តន៍ជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។

- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែមីនា ឆ្នាំ២០២៦ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ១១៨សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៨សំណើ។
- បានថតចម្លងឯកសារ ចំនួន២,៧៣២ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន១៨,៩៤៨សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ១១១លើក ស្មើនឹង២៤៦នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៩លើក។
- បានទទួលលិខិតចូល ចំនួន២៤៦ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន២៧៩ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣១ច្បាប់ ស្មើនឹង១៦៩នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៩នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមានៈ
    - បានដាំដើមជ្រៃ នៅសួនច្បារច្រកចេញ-ចូល P2 ចំនួន២០គុម្ព។
    - បានដាំស្មៅកាដុមថង នៅសួនច្បារជាប់របងក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន១ប្លង់។
    - បានគាស់ប្តូរទីតាំងដើមឫស្សី និងជញ្ជូនផើងមកដាំនៅសួនច្បារខាងក្រោយចំណតរថយន្តដើមជ្រៃ ចំនួន១៧ផើង។
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៤លើក។
    - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
    - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារអគារភក្តីវិក្រម។
- បានចុះពិនិត្យការបណ្តុះកេសរកូល នៅខេត្តបាត់ដំបង និងដួបជាងចម្លាក់ (ជួសជុលអង្គរ) នៅ

ខេត្តសៀមរាប ដើម្បីសាកសួរព័ត៌មានអំពីការធ្លាក់ចម្លាក់នានា ពាក់ព័ន្ធនឹងការកែសម្រួលសួនច្បារទល់មុខអគារភក្ដីវិក្រម។

- បានបន្តរៀបចំខិត្តប័ណ្ណអគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំខែមីនា ឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖
    - មន្ត្រីរាជការក្របខណ្ឌ ចំនួន៧២១នាក់ (ស្រី២៩១) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៦នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩១នាក់ និង
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន១២២នាក់ (ស្រី៥៩នាក់)។
- បានធ្វើសេចក្ដីសម្រេច ចំនួន១០ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៦ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមីនា ឆ្នាំ២០២៦។
- បានរៀបចំវគ្គបណ្ដុះបណ្ដាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន២វគ្គ មានសិក្ខាកាម ចំនួន៦៣នាក់។
- បានសម្របសម្រួលជូនមន្ត្រីរាជការចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា នៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន៥វគ្គ មានសិក្ខាកាម ចំនួន១១នាក់។
- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
    - បានជួសជុលបង្កាន់ដៃម៉ាប និងដំឡើងសសរអ៊ីណុក នៅអគារវិមានសាមគ្គីភាព។
    - បានកាត់ទូ MC បិទជញ្ជាំង ដាក់ទូរទស្សន៍ បិទស្នាមរីសតាមជញ្ជាំង និងបិទប្រឡោះពិដានតាមផ្លូវដើរ នៅអគារធម្មវិជ័យ។
    - បានធ្វើជើងទម្រដែកមានកង់ និងជើងទម្រម៉ាកែត ដាក់នៅអគារធម្មវិជ័យ និងអគារវិមានសាមគ្គីភាព។
    - បានពង្រីកផ្លូវចំណតរថយន្តក្រោមដើមជ្រៃ និង
    - បានដំឡើងសំយ៉ាបនៅប៉ុស្តិ៍យាម P4។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត កំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន១០៨គ្រឿង/លើក។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦។

**៨.៣-ការងារសេវាច្បាប់៖**

- បានប្រមូលផ្តុំចងក្រងឯកសារ និងបោះពុម្ពសៀវភៅស្តីពី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានទទួលសៀវភៅច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ភាគ១ ភាគ២ និងភាគ៣ ចំនួន២៣៤ក្បាល និង
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និង រៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៦៩លើក។

**៨.៤-ការងារស្រាវជ្រាវ៖**

- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន១ច្បាប់ ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។
- បានសិក្សាអំពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង គោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានសិក្សាស្រាវជ្រាវ តាមដាន និងចងក្រងលើ៖
    - ផែនការយុទ្ធសាស្ត្រទំនើបកម្មរថយន្តដឹកទំនិញធន់ធ្ងន់ ឆ្នាំ២០២២-២០៣០។
    - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា និងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង
    - របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គមប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែមីនា ឆ្នាំ២០២៦ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២២៨ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៦-១២ ឆ្នាំ២០២៥)។

**៨.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៦លើក។

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,៧១១លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៣០៥លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន១លើក។
- បានតាំងពិព័រណ៌រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន ១០លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាឌីជីថល ចំនួន ៤៤ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៧៦គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៧០លើក។
- បានទទួលឯកសារ ទស្សនាវដ្តី សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៤៥ក្បាល ព្រមទាំងបានបោះត្រាសៀវភៅ ដាក់លេខកូដសៀវភៅ អ៊ុតក្របសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន១១០ក្បាល។
- បានរៀបចំបញ្ចូលឯកសារ សៀវភៅជា E-Book លើផ្នែកច្បាប់ និងសៀវភៅដែលទាញចេញពីគេហទំព័ររបស់បណ្ណាល័យនានា ក្នុងគេហទំព័រ www.elibrary.senate.gov.kh ចំនួន ១០ក្បាល។
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងរក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបាន៖
    - រៀបចំឯកសាររបស់នាយកដ្ឋានរដ្ឋបាល ឆ្នាំ២០០៤-២០០៥ ចំនួន១៣៥សំណុំលិខិត និង
    - ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន ៤៤សំណុំ។

**៥.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣០លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតជូនពរ លិខិតអបអរសាទរ និងលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ចំនួន២៦លិខិត។

- បានរៀបចំលិខិតឆ្លើយតប កំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១២ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០២៦ ចំនួន១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់ និង
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគ្រួសារ ចំនួន១៨រូប និងលិខិតឆ្លងដែនផ្លូវការជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២រូប។

### ៩.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៦ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែមីនា ឆ្នាំ២០២៦។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមីនា ឆ្នាំ២០២៦ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤៤លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែមីនា ឆ្នាំ២០២៦ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែមេសា ឆ្នាំ២០២៦

## ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបើកសម័យប្រជុំលើកទី៥ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

## ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាល នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាៈ
    - អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និង
    - អញ្ជើញចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមបញ្ជូនសារលិខិតជូនពរ គោរពជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០។
- ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទៅកាន់សហគមន៍អឺរ៉ុប។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាត IPU លើកទី១៥២ នៅសាធារណរដ្ឋតួកគីយ៉េ។
- ត្រៀមសម្របសម្រួលជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមៈ
    - កិច្ចប្រជុំគណៈកម្មការអប់រំ វប្បធម៌ និងទំនាក់ទំនង និងកិច្ចប្រជុំបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង APF នៅទីក្រុងលីប្រឺវីល ប្រទេសហ្គាបុង។
    - សន្និសីទរបស់អង្គការ Women Deliver សម្រាប់ឆ្នាំ២០២៦ នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី និង

- កិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងព័រល្វី កោះម៉ូរីស។

- ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទប្រធានសភានៃអន្តរសភា(ISC) លើកទី២ នៅរាជធានីភ្នំពេញ។
- ត្រៀមចូលរួមសហការរៀបចំកិច្ចប្រជុំកំពូលក្រុមប្រទេសនិយាយភាសាបារាំង ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ នាខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមរៀបចំពិធីសម្ពោធជាផ្លូវការអគារថ្មីនៃព្រឹទ្ធសភា។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព និង
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

## III-សេចក្តីសន្និដ្ឋាន

ក្នុងខែមីនា ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារយ៉ាងសកម្ម និងទូលំទូលាយលើគ្រប់មុខងារសំខាន់ៗ រួមមាន មុខងារនីតិកម្ម តាមដានការអនុវត្តច្បាប់ មុខងារតំណាង កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍន៍ស្ថាប័ន។ ក្នុងរយៈពេលវិស្សមកាលរបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជាអាទិភាពជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការចុះជួបប្រាស្រ័យជាមួយអាជ្ញាធរនៅមូលដ្ឋាន ដើម្បីតាមដានការអនុវត្តច្បាប់ ជួបពិភាក្សាការងារជាមួយអង្គបោះឆ្នោត ពង្រឹងសេវាសាធារណៈ តាមដានវឌ្ឍនភាពការងារ និងការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ប្រព្រឹត្តទៅតាមផែនការគ្រោងទុក។

ជាមួយគ្នានេះ ការអភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្ស និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានអនុវត្តបន្ត ដើម្បីធានាប្រសិទ្ធភាពការងារ ក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំឱ្យកាន់តែប្រសើរ។

សម្រាប់ខែមេសា ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានឹងបន្តផ្តោតលើការរៀបចំសម័យប្រជុំពិនិត្យសេចក្តីព្រាងច្បាប់សំខាន់ៗ ការតាមដានការអនុវត្តគោលនយោបាយ ការចុះជួបប្រជាពលរដ្ឋ

ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការរៀបចំសកម្មភាពសំខាន់ៗ រួមទាំងពិធីបុណ្យជាតិផ្សេងៗ។

សរុបការងារនៅខែមីនា បានបង្កើតមូលដ្ឋានរឹងមាំ សម្រាប់ការអនុវត្តទិសដៅការងារខែមេសា ដើម្បីបន្តលើកកម្ពស់ប្រសិទ្ធភាពស្ថាប័ន និងបម្រើប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡាយ សំកុល**